# សេចក្តីថ្លែងការណ៍រួម

## សូមដោះលែង អ្នកសារព័ត៌មានបរិស្ថាន លោក អ៊ុក ម៉ៅ

### ភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥

យើងខ្ញុំ ជាអង្គការសង្គមស៊ីវិល សមាគមសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សដែលមានរាយនាមខាងក្រោម ព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការចាប់ខ្លួនដោយមិនត្រឹមត្រូវ មកលើអ្នកសារព័ត៌មានផ្នែកបរិស្ថាន លោក អ៊ុក ម៉ៅ ក្រោយពីលោករាយការណ៍អំពីការកាប់បំផ្លាញព្រៃឈើ ។ បច្ចុប្បន្ន លោកកំពុងត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តស្ទឹងត្រែង និងត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងបរិហារកេរ្តិ៍ជាសាធារណៈ ។ យើងខ្ញុំអំពាវនាវ សូមឱ្យលើកលែងការចោទប្រកាន់ និងដោះលែងលោក ម៉ៅ ជាបន្ទាន់ និង គ្មានលក្ខខណ្ឌ ។

លោក អ៊ុក ម៉ៅ ត្រូវបានអាជ្ញាធរចាប់ខ្លួននៅផ្ទះរបស់លោក កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៥ វេលាថ្ងៃត្រង់ ។ ក្នុងចំណោមអាជ្ញាធរទាំងពីរ មានម្នាក់ស្លៀកពាក់ស៊ីវិល ។ នៅពេលចាប់ខ្លួន អាជ្ញាធរទាំងពីរនាក់នោះ មិនបង្ហាញដីកាចាប់ខ្លួននោះទេ ។ ភរិយារបស់លោក ម៉ៅ បានលើកឡើងថា មន្ត្រីទាំងនោះបានប្រាប់ស្វាមីរបស់គាត់ថា «មេរបស់ពួកគេចង់ជួបនិយាយជាមួយគាត់អំពីរឿងដីធ្លីមួយកន្លែង» ។

ការចាប់ខ្លួននេះបានកើតឡើងក្រោយពេលដែលលោកទទួលរងនូវការការបំភិតបំភ័យ គំរាមកំហែង និងអំពើហិង្សា ចាប់តាំងពីខែមិថុនា ឆ្នាំ២០២៤ ។ លោកត្រូវបានកងរាជអាវុធហត្ថសាកសួរ ក្រោយពេលលោក ចុះស៊ើបអង្កេតករណីកាប់រានដីនៅក្នុងព្រៃសហគមន៍ ភ្នំជម្រកសត្វ នៅខេត្តស្ទឹងត្រែង ។ នៅខែសីហា ឆ្នាំ២០២៤ លោកបានជួយ Mongabay លាតត្រដាង អំពីក្រុមហ៊ុនរ៉ែមួយដែលជាប់ពាក់ព័ន្ធនឹងយោធាកម្ពុជា កំពុងកាប់ឈើនៅទីនោះ ។ បន្ទាប់ពី Mongabay ចេញផ្សាយអត្ថបទនេះនៅក្នុងខែកញ្ញា លោក ម៉ៅ ត្រូវបានចោទប្រកាន់ពីបទឈូសឆាយដីព្រៃរបស់រដ្ឋដោយខុសច្បាប់ ទោះបីជាលោកមានប្រវត្តិការងារយ៉ាងច្រើនលើការការពារព្រៃឈើនៅកម្ពុជាក៏ដោយ។

នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៥ លោកត្រូវបានមនុស្សបីនាក់ ដែលត្រូវបានគេស្គាល់ថា ជាអតីតមន្ត្រីថ្នាក់ខេត្ត វាយប្រហារ ខណៈពេលដែលលោកត្រឡប់មកពីប្រមូលព័ត៌មានអំពីការកាប់បំផ្លាញព្រៃឈើខុសច្បាប់នៅក្នុងសហគមន៍ព្រៃឡង់ ។ មនុស្សទាំងបីនាក់ ទាមទារឱ្យលោកលុបរូបភាព និងវីដេអូ ដែលលោកថតបាននៅក្នុងព្រៃ ។ អំពើវាយប្រហារនេះបានបណ្តាលឱ្យលោករងរបួសស្រាល ហើយទូរស័ព្ទរបស់លោកត្រូវបានបំផ្លាញ។ ក្រោយមកលោកបានដាក់ពាក្យបណ្តឹងទៅនគរបាលស្រុកកាលពីថ្ងៃទី២៦ ខែមីនា ប៉ុន្តែលោកត្រូវបានគេប្រាប់មកវិញថា មានគេដាក់ពាក្យបណ្តឹងបកប្រឆាំងនឹងលោកវិញ ហើយអាជ្ញាធរបានមិនបានប្រាប់ពីអត្តសញ្ញាណរបស់អ្នកប្តឹងនោះទេ ។ មិនតែប៉ុណ្ណោះ អាជ្ញាធរបានប្រាប់ឱ្យលោក លុបវីដេអូដែលលោកបានបង្ហោះ នៅលើបណ្តាញសង្គមរបស់លោក អំពីការវាយប្រហារនោះទៀតផង ។ ក្រោយមកនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៥ សាលាដំបូងខេត្តស្ទឹង

ត្រែងបានចេញដីកាកោះហៅលោក ម៉ៅ ឱ្យលោកចូលខ្លួននៅថ្ងៃទី២០ ខែឧសភា ទាក់ទងនឹងឧបទ្ទវហេតុ ដែលបានកើតឡើងកាលពីថ្ងៃទី២៤ ខែមីនា។

លោក ម៉ៅ កំពុងប្រឈមមុខនឹងពាក្យបណ្តឹងផ្លូវច្បាប់រហូតដល់ ១៥ ករណី ដែលនេះជាការបង្កឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីការប្រើប្រាស់ប្រព័ន្ធតុលាការ ដើម្បីព្យាយាមបំបិទសំឡេង ឬសកម្មភាពរាយការណ៍ ពីបញ្ហាបរិស្ថានរបស់លោក ។ ការទទួលរងបណ្តឹងជាច្រើនករណី ដែលករណីនីមួយៗមាននូវទម្ងន់ទោសពន្ធនាគារ និងពិន័យជាប្រាក់យ៉ាងច្រើន គឺជាបន្ទុកមួយដ៏ធ្ងន់ផ្នែកផ្លូវច្បាប់ និងហិរញ្ញវត្ថុ សម្រាប់រូបលោក ដែលមាន គោលបំណងមិនឱ្យលោកបន្តរាយការណ៍អំពីបទល្មើសព្រៃឈើ និងបរិស្ថាន តទៅទៀត ។ នេះគឺជាតថភាពមួយ នៃឥទ្ធិពលនៃការរាយការណ៍របស់លោក អំពីការជាប់ពាក់ព័ន្ធរបស់បុគ្គលមានអំណាច ជាមួយនឹងបទល្មើសព្រៃឈើ និងបរិស្ថាននៅកម្ពុជា ។

ការចាប់ខ្លួន និងចំណាត់ការផ្លូវច្បាប់ទៅលើលោក អ៊ុក ម៉ៅ គឺជាផ្នែកមួយនៃការព្យាយាមបំភិតបំភ័យ និងបំបិទសំឡេងអ្នកសារព័ត៌មាន និងអ្នកការពារបរិស្ថាននៅកម្ពុជា ដែលអ្នកទាំងនោះតែងតែលាតត្រដាង នូវការកេងប្រវ័ញ្ចធនធានធម្មជាតិ និងបុគ្គលដែលប្រព្រឹត្តិអំពើកេងប្រវ័ញ្ចទាំងនេះ ។ អំពើបំភិតបំភ័យ និង រំលោភបំពានផ្សេងទៀត រួមមានការចាប់ខ្លួនសកម្មជនបរិស្ថានមាតាធម្មជាតិចំនួនប្រាំមួយនាក់ និងការហាមឃាត់អ្នកសារព័ត៌មានបរិស្ថានអន្តរជាតិ លោក Gerald Flynn។ មនុស្សមួយចំនួនដែលទទួលផលប្រយោជន៍ទាំងផ្នែកហិរញ្ញវត្ថុ និងនយោបាយ ពីការកាប់បំផ្លាញព្រៃឈើ និងធនធានធម្មជាតិ តែងតែជាបុគ្គលដែលមានតួនាទីខ្ពស់ ដែលជាហេតុធ្វើឱ្យការលាតត្រដាងអំពីអំពើខុសច្បាប់ទាំងនោះ តែងតែទទួលរងនូវការរំលោភបំពានតាមរយៈប្រព័ន្ធតុលាការ ។

ក្នុងឆ្នាំ២០២៤ សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) បានកត់ត្រាករណីយាយីចំនួន ៤១ ករណី ដែលប៉ះពាល់ដល់អ្នកសារព័ត៌មាន ៦៤ នាក់ ។ ការយាយីតាមផ្លូវច្បាប់គឺកើតឡើងច្រើនបំផុត ដោយមានអ្នកសារព័ត៌មានប្រាំនាក់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន និងម្នាក់ត្រូវបានសម្លាប់ខណៈពេលបំពេញការងារសារព័ត៌មានរបស់ខ្លួន ។ នៅដើមឆ្នាំ ២០២៥ អ្នកសារព័ត៌មានបីនាក់ទៀតត្រូវបានឃុំខ្លួន និងចោទប្រកាន់ពីបទញុះញង់។ យោងតាមអង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (RSF) សេរីភាពសារព័ត៌មាននៅកម្ពុជាបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដោយបានធ្លាក់ចុះ ៣៣ លេខក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោករបស់ RSF ចាប់តាំងពីឆ្នាំ២០១៦ និងជាប់ចំណាត់ថ្នាក់ទី ១៦១ ក្នុងចំណោមប្រទេសចំនួន ១៨០ ក្នុងឆ្នាំ២០២៥។

យើងខ្ញុំអំពាវនាវដល់អាជ្ញាធរកម្ពុជាឱ្យ៖

- ដោះលែងលោក អ៊ុក ម៉ៅ ជាបន្ទាន់ និងគ្មានលក្ខខណ្ឌ និងធានាឱ្យមានការស៊ើបអង្កេតឯករាជ្យ មិនលម្អៀងទៅលើហិង្សាដែលកើតឡើងមករូបលោកកាលពីថ្ងៃទី២៤ ខែមីនា
- បញ្ឈប់រាល់ទម្រង់នៃការធ្វើទុក្ខបុកម្នេញតាមផ្លូវតុលាការ និងការគំរាមកំហែងប្រឆាំងនឹងលោក អ៊ុក ម៉ៅ និង អ្នកសារព័ត៌មានដទៃទៀត ជាពិសេសអ្នករាយការណ៍ពី បញ្ហាបរិស្ថាន និងជំលោះដីធ្លី

- ធានាសិទ្ធិសេរីភាពបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងការការពារអ្នកសារព័ត៌មាន ស្របតាមរដ្ឋធម្មនុញ្ញកម្ពុជា និងកាតព្វកិច្ចរបស់ខ្លួនស្ថិតក្រោមច្បាប់អន្តរជាតិ។

ការកំណត់មុខសញ្ញាមកលើអ្នកសារព័ត៌មានតាមរយៈការប្រើប្រាស់អំពើហិង្សា គំរាមកំហែង និងរំលោភបំពានតាមផ្លូវតុលាការ មិនត្រឹមតែជាការរំលោភបំពានលើសិទ្ធិសេរីភាពបុគ្គលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរំលោភបំពានលើលទ្ធិប្រជាធិបតេយ្យ ការទុកចិត្តពីសាធារណជន និង អភិបាលកិច្ចបរិស្ថានផងដែរ ។ ករណីរបស់លោក អ៊ុក ម៉ៅ មិនត្រូវក្លាយជាឧទាហរណ៍មួយទៀតនៃនិទណ្ឌភាព និង ការគាបសង្កត់នោះទេ។

យើងរួមគ្នាជាសាមគ្គីភាពជាមួយអ្នកសារព័ត៌មានទាំងអស់ ដែលក្លាហានដើម្បីរាយការណ៍ពីឧក្រិដ្ឋកម្មបរិស្ថាន និងការពារផលប្រយោជន៍សាធារណៈ។

សេចក្តីថ្លែងការណ៍រួមនេះត្រូវបានគាំទ្រ៖

1. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
2. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
3. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
4. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក)
5. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)
6. សម្ព័ន្ធអ្នកសារព័ត៌មានឯករាជ្យ (AJI)
7. Gerakan Media Merdek (Geramm)
8. មជ្ឈមណ្ឌលដើម្បីសារព័ត៌មានឯករាជ្យ (CIJ)
9. សហជីពជាតិអ្នកសារព័ត៌មាន ហ្វីលីពីន (NUJP)
10. ក្លឹបអ្នកសារព័ត៌មានបរទេសនៅកម្ពុជា (OPCC)
11. អង្គការគណៈកម្មាធិការដើម្បីការពារអ្នកសារព័ត៌មាន (CPJ)
12. វិទ្យាស្ថានកម្ពុជាដើម្បីប្រជាធិបតេយ្យ (CID)
13. មជ្ឈមណ្ឌលធនធានធុរកិច្ច និងសិទ្ធិមនុស្ស (Business & Human Rights Resource Centre)
14. អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (RSF)